

# រឿងរ៉ាវអំពីពិធីបុណ្យជ្រមុជទឹក

*ម៉ាក់បាននិយាយថា ៖ « អ្នកត្រួសត្រាយផ្លូវគឺជាអ្នកដែលធ្វើអ្វីមួយមុនគេ » ។*

ដោយ ណូអែល ឡាមបឺត បារ៉ុស
( ផ្អែកទៅលើដំណើររឿងពិត )

*ដំណើររឿងនេះបានកើតឡើងនៅ ស.រ.អា. ។*

ម៉ារីងក់ក្បាល ហើយសរសើររ៉ូបពណ៌សរបស់នាងនៅក្នុងកញ្ចក់ ។ វាជារ៉ូបដែលម្ដាយនាងស្លៀកនៅពិធីបុណ្យជ្រមុជទឹករបស់គាត់ ។ លោកយាយម៉ាលូស បានសារ៉េវាឲ្យត្រូវនឹងម៉ារី ។ ឥឡូវនេះ ម៉ារីអាចពាក់វានៅពិធីបុណ្យជ្រមុជទឹករបស់នាងផ្ទាល់ !

« កូនស្អាតណាស់ ! » ម៉ាក់បានចាប់ដៃម៉ារី ហើយបានបង្វិលនាងម្ដងទៀត ។

ម៉ារី សើចកក្អឹក ។ « តើកូនអាចពាក់វាពេញមួយថ្ងៃបានទេ ? »

ម៉ាក់បាននិយាយថា « ទុកវាពាក់សម្រាប់ពិធីបុណ្យជ្រមុជទឹករបស់កូនវិញ ដើម្បីឲ្យវានៅស្អាត ហើយអត់ប្រឡាក់ណាកូន ? » ។

« ចាសម៉ាក់ » ។ ម៉ារីនឹងទទួលបុណ្យជ្រមុជទឹកពេលនាងមានអាយុប្រាំបីឆ្នាំ ហើយនាងបានរៀបចំខ្លួនអស់មួយរយៈមកហើយ ។ នាងបានទៅថ្នាក់កុមារ អានព្រះគម្ពីរ ហើយក៏បានទៅពិធីបុណ្យជ្រមុជទឹករបស់មិត្តភក្ដិនាងផងដែរ ។ ប៉ុន្តែថ្ងៃខួបកំណើតរបស់នាងហាក់ដូចជានៅយូរណាស់ !

ម៉ារីឱបម៉ាក់នៅលើសាឡុង ។ « ម៉ាក់ តើម៉ាក់មានអាយុប៉ុន្មាន ពេលម៉ាក់បានទទួលបុណ្យជ្រមុជទឹក ? »

« ម៉ាក់មានអាយុ ១៦ ឆ្នាំ ។ »

« អស្ចារ្យណាស់ ! » ហេតុអ្វីបានជាម៉ាក់រង់ចាំយ៉ាងយូរដូច្នេះ ? »

ម៉ាក់ឱបម៉ារីយ៉ាងណែន ។ « ដោយសារម៉ាក់មិនបានដឹងអំពីសាសនាចក្ររបស់ព្រះយេស៊ូវគ្រីស្ទដែលបានស្ដារឡើងវិញរហូតដល់ពេលនោះ ។ ប៉ុន្តែម៉ាក់បានចាប់ផ្ដើមទៅសកម្មភាពសាសនាចក្រជាមួយមិត្តភក្ដិមួយចំនួន ។ ហើយពេលម៉ាក់បានរៀនកាន់តែច្រើន ម៉ាក់កាន់តែចង់ទទួលពិធីបុណ្យជ្រមុជទឹកកាន់តែខ្លាំងឡើង ! »

« ហេតុអ្វី ? » ម៉ារីបានសួរ ។

« ដោយសារម៉ាក់ចង់មានគ្រួសារជានិរន្តរ៍មួយ » ។ ម៉ាក់បានចង្អុលទៅរូបភាពព្រះវិហារបរិសុទ្ធដែលព្យួរនៅចំពីលើពួកគេ ។ « ម៉ាក់បានរៀនថាថ្ងៃណាមួយម៉ាក់អាចផ្សារភ្ជាប់ជាមួយគ្រួសារម៉ាក់នៅក្នុងព្រះវិហារបរិសុទ្ធជារៀងរហូត ។ ការមានគ្រួសារជានិរន្តរ៍មួយ គឺជាក្ដីសុបិនរបស់ម៉ាក់ ។ ហើយពិធីបុណ្យជ្រមុជទឹកគឺជាជំហានដំបូង ! ឥឡូវសុបិនរបស់ម៉ាក់ក្លាយជាការពិតហើយ » ។

ម៉ារីបានញញឹម ។ « កូនមានប៉ា ម៉ាឡូរី និងកូនតូច មេវ៉ា ! ប្រាកដណាស់ រួមទាំងម៉ាក់ដែរ » ។

« ចាស ពិតមែនហើយ ។ រួមទាំងលោកយាយអេនដេឡាផងដែរ » ។

« តើលោកយាយបានទទួលពីធីបុណ្យជ្រមុជទឹកជាមួយម៉ាក់ដែរមែនទេ ? »

« គាត់បានរង់ចាំពីរបីឆ្នាំ ។ ប៉ុន្តែនៅពេលណាដែលយើងបានធ្វើដំណើរទៅជិតព្រះវិហារបរិសុទ្ធ យើងចូលចិត្តឈប់ឡាន ហើយមើលទៅព្រះវិហារបរិសុទ្ធណាស់ » ។

ម៉ារីស្រមៃគិតពីម៉ាក់ និងលោកយាយដែលកំពុងមើលទៅព្រះវិហារបរិសុទ្ធជាមួយគ្នា ។ « ចុះប៉ាវិញ ? តើប៉ាមានអាយុប៉ុន្មាន ពេលគាត់ទទួលបុណ្យជ្រមុជទឹក ? »

« ប៉ាអាយុ ១១ ឆ្នាំ » ។

« ហើយពេលនោះប៉ារស់នៅប្រេស៊ីលមែនទេ ? »

ម៉ាក់បាននិយាយថា « មែនហើយ » ។ « មានមនុស្សទូទាំងពិភពលោកដែលកំពុងរៀនសូត្រអំពីព្រះយេស៊ូវ និងពិធីបុណ្យជ្រមុជទឹក ។ ពួកគេភាគច្រើនជាពួកអ្នកត្រួសត្រាយផ្លូវ » ។

« ពួកអ្នកត្រួសត្រាយផ្លូវ ? »

ម៉ាក់បានពន្យល់ថា ៖ « អ្នកត្រួសត្រាយផ្លូវគឺជាអ្នកដែលធ្វើអ្វីមួយមុនគេ » ។

ម៉ារី បានគិតអំពីរឿងនោះ ។ « អ៊ីចឹងដូចដែលម៉ាក់ជាមនុស្សដំបូងគេក្នុងគ្រួសាររបស់ម៉ាក់ដែលបានទទួលពិធីបុណ្យជ្រមុជទឹកដែរមែនទេ ? »

ម៉ាក់បានងក់ក្បាល ហើយញញឹម ។

ភ្លាមនោះ ប៉ាក៏ដើរចូលទៅក្នុងបន្ទប់ ហើយបានប្រជ្រៀតអង្គុយលើសាឡុង ។

« ប៉ា តើប៉ាជាអ្នកត្រួសត្រាយផ្លូវសម្រាប់គ្រួសារប៉ាមែនទេ ? »

« ប្រហែលដែរ ។ បន្ទាប់ពីប៉ាទទួលពិធីបុណ្យជ្រមុជទឹកហើយ ប៉ាបានដឹងថាលោកយាយ រ៉ូស៊ីមីរ ក៏ជាសមាជិកម្នាក់ក្នុងព្រះវិហារយើងដែរ ! ប៉ុន្តែគាត់មិនបានទៅជាច្រើនឆ្នាំហើយ » ។

« ពិតមែនឬ ? តើមានអ្វីកើតឡើងមែនទេ ? »

« ប៉ាបានចាប់ផ្ដើមទៅព្រះវិហារ ។ បន្ទាប់មកបងប្រុសប៉ាបានចាប់ផ្ដើមទៅព្រះវិហារ ហើយលោកយាយរ៉ូស៊ីមីរក៏ទៅដែរ ។ សូម្បីតែលោកយាយ តួត ម៉ាលូស ក៏បានចូលរួមដែរ ! »

ម៉ារីបានស្រមៃថាប៉ាទៅព្រះវិហារដោយខ្លួនឯង បន្ទាប់មកនាំគ្រួសារគាត់បន្ថែមទៀតទៅជាមួយគាត់ ។

ម៉ារី បាននិយាយថា « អស្ចារ្យណាស់ » ។ « កូនចូលចិត្តស្ដាប់រឿងរ៉ាវរបស់ប៉ាម៉ាក់ណាស់ ។ វាធ្វើឲ្យកូនរំភើបចិត្តកាន់តែខ្លាំងដើម្បីទទួលពិធីបុណ្យជ្រមុជទឹក ។

ប៉ាបាននិយាយថា « អរគុណដែលបានសួរប៉ាម៉ាក់នូវសំណួរទាំងអស់នេះ ម៉ារី » ។ « ឥឡូវប៉ាម៉ាក់អាចសួរកូនមួយបានទេ ? »

ម៉ារី បានងក់ក្បាល ។ តើពួកគាត់នឹងសួរអ្វី ?

« ហេតុអ្វីកូនចង់ទទួលបុណ្យជ្រមុជទឹក ? »

ម៉ារីបានគិតអំពីអ្វីដែលនាងបានរៀនពីព្រះគម្ពីរ និងអារម្មណ៍របស់នាងនៅព្រះវិហារ ។ « ដោយសារកូនចង់ដើរតាមព្រះយេស៊ូវ ហើយនៅជាមួយគ្រួសាររបស់កូនជារៀងរហូត » ។

ម៉ាក់ និងប៉ាទាំងពីរបានញញឹម ហើយម៉ារីបានស្រវាឱបឪពុកម្ដាយនាង ។ « កូនស្ទើរតែមិនអាចរង់ចាំបាន ! » ●

